គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី៤ នៃនីតិកាលទី៥

របាយការណ៍សង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី៤ នៃរដ្ឋសភានីតិកាលទី៥ ក្នុងឆ្នាំ២០១៧ រកឃើញថា ប្រសិទ្ធភាពរបស់រដ្ឋសភាត្រូវបានបន្តទម្លាក់ជាងក្នុងឆ្នាំ២០១៦។ អ្វីដែលធ្ងន់ធ្ងរក្នុងរយៈពេលនេះ គឺតំណាងរាស្ត្រនៃគណបក្សកាន់អំណាចបានផ្តួចផ្តើម និងសម្រេចជាឯកបក្សក្នុងការធ្វើវិសោធនកម្មច្បាប់ ស្តីពីគណបក្សនយោបាយ ដើម្បីផ្អាក បញ្ឈប់ ឬរំលាយគណបក្សនយោបាយ និងប្រធាន និងថ្នាក់ដឹកនាំគណបក្សនយោបាយ ហើយជាលទ្ធផលនៃវិសោធនកម្មនេះ គណបក្សសង្គ្រោះជាតិ ដែលជាគណបក្សប្រឆាំងដ៏ធំ និងជាដៃគូប្រជែងជាមួយគណបក្សកាន់អំណាចក្នុងការបោះឆ្នោតត្រូវបានរំលាយ។ ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតទាំង៤ ដែលផ្តោតលើរូបមន្តថ្មីនៃការបែងចែកអាសនៈ ដែលមានប៉ះពាល់ជាអវិជ្ជមាន និងអយុត្តិធម៌ធ្ងន់ធ្ងរចំពោះសំឡេងម្ចាស់ឆ្នោត តំណាងឱ្យឆន្ទៈរបស់ម្ចាស់ឆ្នោតដែលមិនឆ្លុះបញ្ចាំងអំពីសមាមាត្រសន្លឹកឆ្នោតនៃភាពជាតំណាងរាស្ត្រ ក៏ជាបញ្ហាធ្ងន់ធ្ងរ ព្រោះវាត្រូវបានប្រើប្រាស់ដើម្បីបែងចែងអាសនៈទាំងអស់របស់គណបក្សសង្គ្រោះជាតិដែលត្រូវបានរំលាយ។ ការរឹតត្បិតសកម្មភាពការងាររបស់តំណាងរាស្ត្រនៃគណបក្សប្រឆាំង ក្នុងការបំពេញការងាររបស់ខ្លួនដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងការបើកផ្លូវឱ្យក្រសួងមានសមត្ថកិច្ចធ្វើការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន និងឃុំខ្លួន ប្រធានគណបក្សប្រឆាំងជាដើម។

ជាមួយគ្នានេះដែរ សកម្មភាពការងាររបស់គណៈកម្មការជំនាញនៃរដ្ឋសភាវិញ គឺបន្តថយចុះ បើធៀបនឹង រយៈពេលដូចគ្នាក្នុងឆ្នាំទី៣(ឆ្នាំ២០១៦) និងឆ្នាំទី២(ឆ្នាំ២០១៥)។ ដោយឡែក ចំនួនតំណាងរាស្ត្រចុះមូលដ្ឋានក៏មានការថយ ហើយចំនួនសកម្មភាពនៅមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក៏មានការថយចុះតិចតួចផងដែរ បើធៀបនឹងឆ្នាំទី៣។ រីឯចំនួនតំណាងរាស្ត្រឡើងបញ្ចេញមតិក្នុងការពិភាក្សា និងអនុម័តច្បាប់ និងបរិមាណនៃការបញ្ចេញមតិនៅក្នុងកិច្ចប្រជុំពេញអង្គរបស់រដ្ឋសភាវិញ មានកើនឡើងតិចតួច (ចំនួន៣រូប) ប៉ុន្តែបើធ្វើការប្រៀបធៀបនឹង ឆ្នាំ២០១៥ គឺនៅបន្តមានការថយចុះ ដោយក្នុងរយៈពេលនោះមានតំណាងរាស្ត្រចំនួន៤៣រូបបានឡើងបញ្ចេញមតិ។

**ដំណើរការប្រជុំពេញអង្គរបស់រដ្ឋសភា៖** រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គសាមញ្ញ ចំនួន៣លើក និងកិច្ចប្រជុំជាវិសាមញ្ញចំនួន៣លើក។ ក្នុងចំណោមសម័យប្រជុំសាមញ្ញ និងវិសាមញ្ញទាំងនេះ រដ្ឋសភាបានរៀបចំកិច្ចប្រជុំចំនួន១៣កិច្ចប្រជុំ ដោយប្រើរយៈពេលសរុបចំនួន១៤វេន (១៣ព្រឹក និង១រសៀល)។ សម័យប្រជុំសាមញ្ញទាំង៣លើកនោះរួមមានៈ លើកទី១ បន្តសម័យប្រជុំលើកទី៧ (គិតពីចុងខែវិច្ឆិកា ឆ្នាំ២០១៦ ដល់ខែមករា ឆ្នាំ២០១៧) លើកទី២ សម័យប្រជុំលើកទី៨ (គិតពីដើមខែមេសា ឆ្នាំ២០១៧ ដល់ខែកក្កដា ឆ្នាំ២០១៧) និងលើកទី៣ សម័យប្រជុំលើកទី៩ (គិតពីដើមខែតុលា ឆ្នាំ២០១៧)។ ដោយឡែកកិច្ចប្រជុំជាវិសាមញ្ញទាំង៣លើក គឺលើកទី១នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ លើកទី២នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ និងលើកទី៣នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧។

ក្នុងរយៈពេលនេះមានរបៀបវារៈចំនួន២៩ត្រូវលើកមកពិភាក្សា និងអនុម័តដែលរួមមាន៖ ព្រះរាជសាររបស់ព្រះមហាក្សត្រជូនសម័យប្រជុំចំនួន២ របាយការណ៍សង្ខេបចន្លោះសម័យប្រជុំរបស់រដ្ឋសភាចំនួន២ សេចក្តីព្រាង

**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**Central Office** : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

ច្បាប់ចំនួន១២ សេចក្ដីស្នើច្បាប់ចំនួន០៧ សេចក្ដីស្នើវិសោធនកម្មចំនួន០២ ការប្រកាសសុពលភាពនៃអាណត្តិសមាជិករដ្ឋសភារបស់តំណាងរាស្ត្រថ្មីចំនួន០១រូប ការឆ្លើយបំភ្លឺរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ចំនួន០១លើក ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួន០១លើក និងការប្រជុំសម្រេចលើករណីឯកឧត្តម កឹម សុខា តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាមចំនួន០១លើក។

ក្នុងចំណោមកិច្ចប្រជុំរបស់រដ្ឋសភាទាំង១៣កិច្ចប្រជុំ (ទាំងកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញ) ការសង្កេតឃើញថា ការអនុម័តលើសេចក្ដីព្រាងច្បាប់ និងសេចក្ដីស្នើវិសោធនកម្មច្បាប់ចំនួន១៧ ត្រូវបានអនុម័តដោយសំឡេងឯកបក្ស (ដោយគណបក្សប្រជាជនកម្ពុជា) ខណៈពេលដែលគណបក្សសង្គ្រោះជាតិធ្វើពហិការមិនចូលរួមក្នុងកិច្ចប្រជុំចំនួន៦កិច្ចប្រជុំ។ ជាមួយគ្នានេះ អង្គសភាបានអនុម័តលើសេចក្ដីព្រាង/ស្នើច្បាប់ និងការសម្រេចចិត្តចំនួន១២ ដោយគ្មានការជជែកពិភាក្សា ដែលក្នុងនោះ១១សេចក្ដីព្រាង/ស្នើច្បាប់ និងការសម្រេចចិត្ត គឺស្ថិតក្នុង១៧សេចក្ដីព្រាងច្បាប់ និងសេចក្ដីស្នើវិសោធនកម្មច្បាប់ ដែលអនុម័តដោយឯកបក្ស។ ក្រុមការងារតាក់តែងច្បាប់បានអះអាងថា សេចក្ដីព្រាងច្បាប់ដែលបានលើកយកមកពិភាក្សា និងអនុម័តទាំងនោះត្រូវបានពិនិត្យ និងពិភាក្សាដោយគណៈកម្មការជំនាញនៃរដ្ឋសភារួចរាល់អស់ហើយ។

ការសង្កេតឃើញថា ចំនួនអ្នកតំណាងរាស្ត្រឡើងបញ្ចេញមតិ និងបរិមាណនៃការបញ្ចេញមតិមានការកើនឡើងតិចតួច (ចំនួន៣រូប) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំទី៣ ប៉ុន្តែបើធ្វើការប្រៀបធៀបនឹងឆ្នាំ២០១៥ គឺនៅបន្តមានការថយចុះ ដោយក្នុងរយៈពេលនោះមានតំណាងរាស្ត្រចំនួន៤៣រូបបានឡើងបញ្ចេញមតិ។ ក្នុងរយៈពេលនេះមានតំណាងរាស្ត្រចំនួន២១រូប បានឡើងបញ្ចេញមតិ ដែលក្នុងនោះ១៣រូប មកពីគណបក្សប្រជាជនកម្ពុជា និង៨រូបមកពីគណបក្សសង្គ្រោះជាតិ។ ជាការកត់សម្គាល់ ដោយសារការធ្វើពហិការមិនចូលរួមប្រជុំរបស់តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ បានធ្វើឱ្យបរិមាណនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រពីគណបក្សនេះ មានចំនួនតិចជាងតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា។

ខុមហ្វ្រែលបន្តសង្កេតឃើញថា ក្នុងអំឡុងពេលដែលតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិធ្វើពហិការមិនចូលរួមប្រជុំពិភាក្សា តំណាងរាស្ត្រគណបក្សកាន់អំណាចមិនបានពិភាក្សាស៊ីជម្រៅលើរបៀបវារៈនោះទេ ដោយភាគច្រើនធ្វើការអនុម័តសេចក្ដីព្រាងច្បាប់ និងសេចក្ដីស្នើច្បាប់ទាំងនោះតែម្ដង។ ជាក់ស្ដែងក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ ចាប់តាំងពីខែកក្កដា ដល់ខែតុលានេះ រាល់កិច្ចប្រជុំក្នុងកំឡុងពេលនេះ ត្រូវបានអនុម័តដោយគ្មានការបញ្ចេញមតិពីតំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជា។

**សកម្មភាពរបស់គណៈកម្មការជំនាញរបស់រដ្ឋសភា៖** នៅក្នុងឆ្នាំទី៤(ឆ្នាំ២០១៧)នេះ សកម្មភាពរបស់គណៈកម្មការជំនាញនៃរដ្ឋសភាបន្តថយចុះ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំទី៣(ឆ្នាំ២០១៦) និងឆ្នាំទី២(ឆ្នាំ២០១៥)។ ការសង្កេតរកឃើញថា គណៈកម្មការជំនាញទាំង១០នៃរដ្ឋសភាបានធ្វើសកម្មភាពសរុបចំនួន៥៦លើក។ ក្នុងចំណោមសកម្មភាពទាំងនេះ គណៈកម្មការជំនាញនៃរដ្ឋសភាដឹកនាំដោយគណបក្សប្រជាជនកម្ពុជា មានសកម្មភាពចំនួន៣២លើក ហើយសកម្មភាពគណៈកម្មការជំនាញនៃរដ្ឋសភាដឹកនាំដោយគណបក្សសង្គ្រោះជាតិមានចំនួន២៤លើក។ សកម្មភាពថយចុះរបស់គណៈកម្មការជំនាញ ជាពិសេសគណៈកម្មការដែលដឹកនាំដោយគណបក្សសង្គ្រោះជាតិ អាចបណ្ដាលមកពីតំណាងរាស្ត្រពីគណបក្សនេះធ្វើពហិការមិនចូលធ្វើការក្នុងរដ្ឋសភា នៅពេលមានការខ្វែងគំនិតលើកកិច្ចការមួយចំនួនរបស់រដ្ឋសភា។

ក្នុងរយៈពេលនេះ មានរដ្ឋមន្ត្រីចំនួន៣រូប ត្រូវបានកោះហៅមកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងគណៈកម្មការជំនាញនៃរដ្ឋសភា។ សកម្មភាពនេះមានការកើនឡើង បើធៀបនឹងឆ្នាំ២០១៦ ដែលមានតែមួយលើកប៉ុណ្ណោះ។

ក្នុងចំណោមសកម្មភាពទាំងនោះ គណៈកម្មការជំនាញទី១ មានសកម្មភាពចំនួន០៤លើក គណៈកម្មការជំនាញទី២ មានសកម្មភាពចំនួន០៦លើក គណៈកម្មការជំនាញទី៣ មានសកម្មភាពចំនួន០៦លើក គណៈកម្មការជំនាញទី៤ មានសកម្មភាពចំនួន០២លើក គណៈកម្មការទី៥ មានសកម្មភាពចំនួន១៤លើក គណៈកម្មការជំនាញទី៦ មានសកម្មភាពចំនួន០៨លើក គណៈកម្មការទី៧ មានសកម្មភាពចំនួន០៧លើក គណៈកម្មការទី៨ មានសកម្មភាពចំនួន០៥លើក គណៈកម្មការទី៩ មានសកម្មភាពចំនួន០២លើក និងគណៈកម្មការជំនាញទី១០ មានសកម្មភាពចំនួន០២លើក។

**សកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រ៖** ក្នុងរយៈពេលនេះ ចំនួនសកម្មភាពនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមានការថយចុះតិចតួច បើធៀបនឹងឆ្នាំទី៣ (ឆ្នាំ២០១៦) ប៉ុន្តែទោះជាយ៉ាងណា វាជាចំនួនច្រើនបើប្រៀបធៀបទៅនឹងឆ្នាំទី១ និងឆ្នាំទី២។ មិនខុសពីឆ្នាំ២០១៦ គោលបំណងក្នុងការចុះមូលដ្ឋានភាគច្រើនរបស់តំណាងរាស្ត្រគឺដើម្បីពង្រឹងបណ្ដាញរបស់ខ្លួន និងទាក់ទាញប្រជាប្រិយភាព និងការគាំទ្រមកលើគណបក្សរបស់ខ្លួន ព្រោះជាឆ្នាំដែលមានរៀបចំការបោះឆ្នោតសកល។

ខុមហ្វ្រែលសង្កេតឃើញថា មានតំណាងរាស្ត្រចំនួន៨៣រូប បានចុះធ្វើសកម្មភាពក្នុងមូលដ្ឋានសរុបចំនួន១៧៩៥លើក។ បើធៀបនឹងឆ្នាំទី៣ ឆ្នាំ២០១៦ក្នុងរយៈពេលដូចគ្នាឃើញថា មានការថយចុះចំនួនតំណាងរាស្ត្រចុះមូលដ្ឋាន និងថយចុះតិចតួចនៃចំនួនសកម្មភាពរបស់តំណាងរាស្ត្រ។ ក្នុងចំណោមសកម្មភាពទាំងនោះ មានតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចំនួន៤៣រូប ចុះធ្វើសកម្មភាពសរុបចំនួន៧៤២លើក ខណៈដែលតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិចំនួន៤0រូប ចុះធ្វើសកម្មភាពសរុបចំនួន១០៥៣លើក។ សកម្មភាពទាំងនោះភាគច្រើន គឺផ្ដោតលើការចុះពង្រឹងបណ្ដាញផ្ទៃក្នុងរបស់គណបក្សនៅមូលដ្ឋាន និងការជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ។

**ការកោះហៅបំភ្លឺ៖** អំឡុងពេលនេះ រដ្ឋសភាបានកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺក្នុងកិច្ចប្រជុំរដ្ឋសភាពេញអង្គចំនួន១លើក ដូចគ្នានឹងឆ្នាំទី៣ (ឆ្នាំ២០១៦)។ ដោយឡែក ការកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺក្នុងកិច្ចប្រជុំគណៈកម្មការជំនាញរបស់រដ្ឋសភាមានចំនួន៣លើក ដែលមានការកើនឡើង បើធៀបនឹងឆ្នាំ២០១៦ ដែលមានតែមួយលើកប៉ុណ្ណោះ។

**កិច្ចអន្តរាគមន៍របស់រដ្ឋសភា និងតំណាងរាស្ត្រ៖** ទាក់ទិននឹងបញ្ហានេះ ខុមហ្វ្រែលសង្កេតឃើញថា មានការកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺនៅក្នុងកិច្ចប្រជុំរដ្ឋសភា និងកិច្ចប្រជុំរបស់គណៈកម្មការជំនាញ ការទទួលបណ្ដឹង និងការអន្តរាគមន៍លើបណ្ដឹងរបស់ប្រជាពលរដ្ឋ។ ក្នុងរយៈពេលនេះរដ្ឋសភា បានទទួលបណ្ដឹងដោយផ្ទាល់ពីប្រជាពលរដ្ឋដែលបានមកដាក់ញត្តិនៅរដ្ឋសភាចំនួន១១បណ្ដឹង។ ភាគច្រើននៃបណ្ដឹងរបស់ប្រជាពលរដ្ឋ គឺស្នើសុំកិច្ចអន្តរាគមន៍ពីរដ្ឋសភា ដើម្បីជួយដោះស្រាយវិវាទនានា ជុំវិញបញ្ហាដីធ្លី និងវិវាទការងារ វិបត្តិទីផ្សារ និងការស្នើដោះលែងសកម្មជនភូមិបឹងកក់ (អ្នកស្រីទេព វន្នី)។ គួរបញ្ជាក់ថា ក្នុងឆ្នាំ២០១៦ ខុមហ្វ្រែលទទួលព័ត៌មានថា រដ្ឋសភាបានទទួលបណ្ដឹងដោយផ្ទាល់នៅរដ្ឋសភា និងតាមមូលដ្ឋានមានចំនួន២១បណ្ដឹង ហើយក្នុងឆ្នាំ២០១៥ មានចំនួន២៥បណ្ដឹង។

**ចំនួនលិខិតអន្តរាគមន៍ និងដោះស្រាយ៖** ក្នុងរយៈពេលនេះ ខុមហ្វ្រែលទទួលព័ត៌មានអំពីការចេញលិខិតរបស់អ្នកតំណាងរាស្ត្រមានចំនួន១៩ច្បាប់។ ចំនួននេះមានការថយចុះ បើធៀបនឹងរយៈពេលដូចគ្នាក្នុង២០១៦ ដែលក្នុងរយៈពេលនោះមានចំនួន២៤ច្បាប់។ លិខិតទាំងនោះមានថ្វាយ និងផ្ញើជូនព្រះមហាក្សត្រ រាជរដ្ឋាភិបាល និងរដ្ឋសភា ហើយធ្វើឡើងដោយក្រុមអ្នកតំណាងរាស្ត្រក្នុងគោលបំណងអំពាវនាវចាត់វិធានការ និងស្នើសុំការអន្តរាគមន៍ដើម្បីដោះស្រាយបញ្ហានានា។ លិខិតទាំង១៧ច្បាប់ ធ្វើឡើងដោយក្រុមតំណាងរាស្ត្រ/តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ។ បើតាមព័ត៌មានដែលខុមហ្វ្រែលទទួលបាន យ៉ាងហោចណាស់លិខិត៤ច្បាប់ទទួលការឆ្លើយតបពីភាគីពាក់ព័ន្ធ។

**តំណាងរាស្ត្រ១០រូប ដែលសកម្មជាងគេ៖** ចំពោះការឡើងបញ្ចេញមតិរបស់តំណាងរាស្ត្រក្នុងកិច្ចប្រជុំពេញអង្គនៃរដ្ឋសភាវិញ តំណាងរាស្ត្រដែលមានសកម្មភាពជាងគេរួមមាន ៥រូប ពីគណបក្សប្រជាជនកម្ពុជារួមមាន ឯកឧត្តម ឈាង វុន ឯកឧត្តម ហ៊ុន ម៉ានី ឯកឧត្តម ម៉ុម ជឹមហ៊ុយ សម្តេច ហ៊ុន សែន និងសម្តេច ស ខេង និង៥រូបពីគណបក្សសង្គ្រោះជាតិរួមមាន ឯកឧត្តម សុន ឆៃ ឯកឧត្តម ងឹម ញេង ឯកឧត្តម លិម គិមយ៉ា ឯកឧត្តម អេង ឆៃអ៊ាង និងឯកឧត្តម ម៉ៅ មុនីវណ្ណ។ ដោយឡែក ចំពោះការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ខុមហ្វ្រែលទទួលព័ត៌មានថា មានតំណាងរាស្ត្រ ៧រូប ពីគណបក្សសង្គ្រោះជាតិរួមមាន ឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ ឯកឧត្តម ម៉ៅ មុនីវណ្ណ ឯកឧត្តមរៀល ខេមរិន្ទ្រ ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ លោកជំទាវ កែ សុវណ្ណរតន៍ ឯកឧត្តម កឹម សុខា និងឯកឧត្តម ទួន យក់ដា និង៣រូប ពីគណបក្សប្រជាជនកម្ពុជារួមមាន លោកជំទាវ ម៉ែន សំអន លោកជំទាវ កែ ច័ន្ទមុនី និងសម្តេច ហ៊ុន សែន។

**សម្រាប់ព័ត៌មានបន្ថែម៖**


| **ឈ្មោះ** | **លេខទូរស័ព្ទ** |
|---|---|
| • លោក គឹម ឈន | ០១២ ៩៤២ ០១៩ |
| • លោក កន សាវ៉ាង្ស | ០១១ ៨៨៤ ៨៤០ |
| • លោក ស៊ិន ទិត្យសីហា | ០១២ ២៥២ ៦៦១ |